អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងបង្កើតចង្រង់ភ្លេង**

**ចិត្តចលភាព** ៖ បំណិនចលនាតូច៖
ការហ្វឹកហាត់បង្កើនកម្លាំងនិងសម្របសម្រួលរវាងចលនាសាច់ដុំដៃនិងសាច់ដុំភ្នែក

**សិក្សាសង្គម** ៖ ចម្រៀងនិងតន្ត្រី៖ ចំណេះដឹងបច្ចេកទេស ចលនា ការច្នៃប្រឌិតនិងបទពិសោធន៍ផ្នែកតន្ត្រី
៖ ការយល់ដឹងនិងការពេញចិត្តចំពោះសិល្បៈតាមរយការបង្កើតរូបភាព
៖ គំនូរនិងសកម្មភាពកសាង៖
ការយល់ដឹងនិងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព

**ភាសាខ្មែរ** ៖ ការស្គាល់តួអក្សរ៖ ការយល់ដឹងអំពីភាពខុសគ្នានៃសូរសំឡេង

**គោលបំណង**

**ចិត្តចលភាព** ៖ បំណិនសម្បទា៖
ប្រាប់បានពីរបៀបធ្វើចលនាដៃដោយការទប់លំនឹង
និងសម្របសម្រួលទៅនឹងភ្នែកក្នុងពេលធ្វើអ្វីមួយ ឬលេងល្បែងអ្វីមួយ។

**សិក្សាសង្គម** ៖ វិជ្ជាសម្បទា៖ ប្រាប់បានពីការទះដៃបន្ទរ ឬគោះសម្ភារនានា តាមចង្វាក់ភ្លេង។
បំណិនសម្បទា៖ ទះដៃបន្ទរ គោះសម្ភារនានាតាមចង្វាក់ភ្លេង។
៖ វិជ្ជាសម្បទា៖ ប្រាប់បានពីរបៀបបត់ រោយ ដេរ ត្បាញ សូនរូប គូរ ផាត់ពណ៌ ហែក កាត់ បិទបត់… ដើម្បីបង្កើតជារូបភាពផ្សេងៗ។

**ភាសាខ្មែរ** ៖ វិជ្ជាសម្បទា៖ប្រាប់បានពីសូរសំឡេងសត្វឬវត្ថុនានានៅក្នុងបរិស្ថាន
បំណិនសម្បទា៖ បង្ហាញពីភាពខុសគ្នានៃសូរសំឡេង

**កម្រិតសិក្សា** ៖ ទាប មធ្យមនិងខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ សម្ភារដែលត្រូវត្រៀមដូចជា៖កាំភ្លើងបាញ់កាវ ចានស្មោគ្រាប់គ្រួស ឬគ្រាប់ធញ្ញជាតិ គម្របដប បន្ទាត់ ហ្វីត និងកាំបិត។

**ការរៀបចំ** ៖ បង្កើតចង្រង់ភ្លេងមួយសម្រាប់បង្ហាញទៅកាន់កុមារ មុននឹងឱ្យកុមារចាប់ផ្តើមលេង ឬបង្កើតនៅក្នុងថ្នាក់ទាំងអស់គ្នា។

**សេចក្តីណែនាំ ៖**

1. ដំបូងសួរកុមារពីឧបករណ៍តន្ត្រីជាមុនសិន ថាតើកុមារស្គាល់វាបានប៉ុន្មាន? ឱ្យកុមាររៀបរាប់ពីឧបករណ៍តន្ត្រីដែលពួកគេស្គាល់ ថាស្គាល់បានប៉ុណ្ណា?
2. ប្រាប់កុមារទាំងអស់ថា ថ្ងៃនេះពួកយើងនឹងបង្កើតឧបករណ៍តន្ត្រីមួយដែលមានឈ្មោះថា ចង្រង់ភ្លេង។
3. ចាប់ផ្តើមប្រាប់កុមារពីរបៀបនៃការធ្វើចង្រង់ភ្លេងដោយខ្លួនឯង
    - ចានស្មោ គូសនៅចំពាក់កណ្តាលចានស្មោ
    - កាត់វាជាពីរចំណែក រួចដាក់វាបែរខ្នងដាក់គ្នា
    - បិទវានៅខាងខ្នងចានស្មោដែលបានកាត់មុនហ្នឹងដោយកាំភ្លើងបាញ់កាវ
    - ដាក់គ្រាប់ធញ្ញជាតិ២ឬ៣គ្រាប់ទៅក្នុងគម្របដប
    - ដាក់វាគ្របចូលគ្នានិងបាញ់កាវបិទវាឱ្យជាប់
    - ចាប់ផ្តើមបិទភ្ជាប់គម្របដបដែលបានដាក់គ្រាប់ធញ្ញជាតិចូលមុនហ្នឹងទាំង៥នៅចន្លោះខ្នងចានស្មោ ដោយប្រើកាំភ្លើងបាញ់កាវឱ្យបានរឹងមាំ។
    - បញ្ជាក់ កន្លែងនេះ អ្នកអាចដាក់លើសពី៥ក៏បានដែរ តាមការចូលចិត្តរបស់អ្នក។